# ផ្នែកទី V ( i )

# បង្គោលសញ្ញា

# Sign Posts

បង្គោលសញ្ញា មានច្រើនប្រភេទ ដែលមានទ្រង់ទ្រាយផ្សេងៗពីគ្នា ដូចជាខ្លះមាន រាងមូល ខ្លះរាងជ្រុង ខ្លះរាងចតុកោណព្នាយ ខ្លះរាងជាបន្ទះ ។ល។

បង្គោលសញ្ញា ប្រើក្នុងគោលបំណងផ្សេងៗគ្នា ដូចជាបង្គោលសំរាប់តំរង់ផ្លូវ សំរាប់ជួយសំរួលអ្នកបើកបរ ពិសេសនៅពេលយប់ អោយងាយដឹងពីការបត់បែនរបស់ផ្លូវ ។ បង្គោលដាក់នៅតាមផ្លូវកោងគ្រោះថ្នាក់ សំរាប់អោយអ្នកបើកបរ ងាយដឹង និងប្រុងប្រយ័ត្ន នៅកន្លែងផ្លូវកោងគ្រោះថ្នាក់ដោយមានចំណោតឡើង ចុះ ឬ មានជ្រោះ ។ បង្គោលដាក់នៅលើ កន្លែងមានឧបសគ្គ ដូចជា ក្បាលស្ពាន ខឿន ឬ សូនច្បារ សំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ។ បង្គោលគីឡូមែត្រ សំរាប់បង្ហាញចំងាយ ទៅតំបន់ផ្សេងៗ ។

## ផ្នែកទី V ( i ) : បង្គោលសញ្ញា ( Sign Posts )



### បង្គោលសញ្ញាផ្លូវកោង ឬ តំរង់ផ្លូវ
DELINEATOR POST

**លេខកូដ : PW03-P1-01**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ អោយដឹង ពីផ្លូវកោងលើផ្ទៃរាបស្មើ ឬប្រើសំរាប់តំរង់ផ្លូវបើកបរមិនអោយងាកចេញពីទ្រូងផ្លូវ ពិសេសនៅពេលយប់ ព្រោះ មានបំពាក់បន្ទះចំណាំងផ្លាត នៅចន្លោះ ផ្ទៃខ្មៅ។

---



### បង្គោលសញ្ញាផ្លូវកោង (កោងគ្រោះថ្នាក់)
GUIDE POST ( AT DENGEROUS CURVE )

**លេខកូដ : PW03-P1-02**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ អោយដឹង ពីផ្លូវកោងគ្រោះថ្នាក់ ដោយចុះឡើងចំណោត ឬ មាត់ជ្រោះ ។

---



### សញ្ញាលើរបារផ្លូវកោងទៅស្តាំ
LATERAL SHIFT MARKER (TO RIGHT)

**លេខកូដ : PW03-P1-03**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរអោយប្រុងប្រយ័ត្ន ផ្លូវកោងទៅស្តាំ ។

---



### សញ្ញាលើរបារផ្លូវកោងទៅឆ្វេង
LATERAL SHIFT MARKER (TO LEFT)

**លេខកូដ : PW03-P1-04**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរអោយប្រុងប្រយ័ត្ន ផ្លូវកោងទៅឆ្វេង ។



## សញ្ញាបង្ហាញឧបសគ្គ នៅខាងស្តាំ

OBJECT MARKER (ON THE RIGHT)

**លេខកូដ : PW03-P1-05**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅខាងស្តាំ ដូចជា បង្គោលក្បាលស្ពាន ឬ ខឿនលើទ្រូងផ្លូវ ។ល។

---



## សញ្ញាបង្ហាញឧបសគ្គ នៅលើទ្រូងផ្លូវ

OBJECT MARKER (AT CENTER)

**លេខកូដ : PW03-P1-06**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅលើទ្រូងផ្លូវឯកទិស ដូចជា ខឿន ឬ សួនច្បារ ។

---



## សញ្ញាបង្ហាញឧបសគ្គ នៅខាងឆ្វេង

OBJECT MARKER (ON THE LEFT)

**លេខកូដ : PW03-P1-07**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅខាងឆ្វេង ដូចជា បង្គោលក្បាលស្ពាន ឬ ខឿនលើទ្រូងផ្លូវ ។ល។

---




## បង្គោលសញ្ញាផ្លូវរថភ្លើងឆ្លងកាត់

RAILWAY CROSSING POST

**លេខកូដ : PW03-P1-08**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់ ផ្តល់ដំណឹងអោយអ្នកបើកបរប្រុងប្រយ័ត្ន មានផ្លូវរថភ្លើងឆ្លងកាត់ ១៥០ម៉ែត្រ ខាងមុខ (រូបទី 1 ), ១០០ម៉ែត្រ ខាងមុខ (រូបទី 2 ) និង ៥០ម៉ែត្រ ខាងមុខ (រូបទី 3 ) ។




**បង្គោលគីឡូម៉ែត្រ (សំរាប់ចន្លោះ ១០គ.ម)**

KILOMETER POST ( FOR 10Km INTERVAL )

**លេខកូដ : PW03-P1-09**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់ ផ្តល់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវ អំពីចំងាយផ្លូវ ទៅតំបន់សំខាន់ៗ ខាងមុខ ។ បង្គោលសញ្ញាប្រភេទនេះ មានក្នុងចន្លោះ ១០ គ.ម មួយ ។

---




**បង្គោលគីឡូម៉ែត្រ (សំរាប់ចន្លោះ ១គ.ម)**

KILOMETER POST ( FOR 1 Km INTERVAL )

**លេខកូដ : PW03-P1-10**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់ ផ្តល់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវ អំពីចំងាយផ្លូវ ទៅតំបន់សំខាន់ៗ ខាងមុខ ។ បង្គោលសញ្ញាប្រភេទនេះ មានក្នុងចន្លោះ មួយ គ.ម មួយ ។